អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ ៥០៤.ណណ.១៧ អអក

ភ្នំពេញ, ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាប័ណ្ណលើកទី២ របស់សេវាករ ចាន់ គឹមអេង សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកភ្នំស្រួច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅស្រុកភ្នំស្រួច និង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាប័ណ្ណលើកទី២ របស់សេវាករ ចាន់ គឹមអេង ដើម្បីធ្វើការប្តូរឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណពីសេវាករ ចាន់ គឹមអេង ទៅឲ្យក្រុមហ៊ុន ចាន់ គឹមអេង អេឡិកទ្រីស៊ីធី ឯ.ក តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដូចមានជូនភ្ជាប់មកជាមួយនេះ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ពន្ធ័ និងសាធារណជន មានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាប័ណ្ណដែលគ្រោងនឹងផ្តល់នេះ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាប័ណ្ណនៅ................ ...............................................................................................សម្រាប់សាធារណជនពិនិត្យ។

អាស្រ័យហេតុនេះ សូមសាធារណជននៅស្រុកភ្នំស្រួច និងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាប័ណ្ណឲ្យសេវាករ ចាន់ គឹមអេង អញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះរហូតដល់ថ្ងៃទី៨ ខែកញ្ញា ២០១៧។

អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **"អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណាដែលមានបង្ហាញនូវហេតុផលយោងច្បាស់លាស់ប៉ុណ្ណោះ"** ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ឌី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

**ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា**

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

# សេចក្តីសម្រេចកែសម្រួលលើកទី២
# លើឯកសារអាជ្ញាបណ្ណលេខ ៣៨៥ ឯអ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកភ្នំស្រួច និងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
# សម្រាប់ការប្តូរឈ្មោះអ្នកកាន់អាជ្ញាបណ្ណពីលោកស្រី ចាន់ គឹមអេង ទៅជាក្រុមហ៊ុន ចាន់ គឹមអេង អេឡិចទ្រិស៊ីធី ឯ.ក

# DECISION ON THE SECOND REVISION

TO THE LICENSE DOCUMENT No. 385 LD DATED JUNE 13, 2014
FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF
PHNOM SRUOCH AND SAMRONG TONG DISTRICTS
KOMPONG SPEU PROVINCE

**FOR CHANGING THE NAME OF LICENSEE FROM MRS. CHAN KIM ENG TO CHAN KIM ENG ELECTRICITY CO., LTD.**

ថ្ងៃទី ខែ ឆ្នាំ២០១៧

, 2017

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖ -១៧.អអក

# សេចក្តីសម្រេចកែសម្រួលលើកទី២
# លើឯកសារអាជ្ញាបណ្ណលេខ ៣៨៥ ឯអ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

# DECISION ON THE SECOND REVISION
# TO THE LICENSE DOCUMENT No. 385 LD DATED JUNE 13, 2014

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 34 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03, dated 02/February/2001.

-យោងឯកសារអាជ្ញាបណ្ណលេខ ៣៨៥ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

- In accordance with License Document No. 385 LD issued by Electricity Authority of Cambodia on June 13, 2014.

-យោងលិខិតស្នើសុំប្តូរឈ្មោះអ្នកកាន់អាជ្ញាបណ្ណរបស់លោកស្រី ចាន់ គីមអេង ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧

- In accordance with the requested letter for changing the name of licensee of Mrs. Chan Kim Eng, dated March 22, 2017.

-យោងតាមការអនុម័តរបស់សម័យប្រជុំ**អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ចុះថ្ងៃទី ខែ ឆ្នាំ២០១៧

- In accordance with the decision of Electricity Authority of Cambodia's Session No , , 2017.

# សម្រេច

**DECIDES**

| | |
|---|---|
| **ប្រការ១**<br><br>កែសម្រួលឯកសារអាជ្ញាបណ្ណលេខ ៣៨៥ ឯអ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ដែលបានផ្តល់ជូនលោកស្រី ចាន់ គឹមអេង ដើម្បីប្តូរឈ្មោះអ្នកកាន់អាជ្ញាបណ្ណពីលោកស្រី **ចាន់ គឹមអេង** ទៅជាក្រុមហ៊ុន **ចាន់ គឹមអេង អេឡិកទ្រីស៊ីធី ឯ.ក** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាបណ្ណ**") មានទីស្នាក់ការនៅភូមិត្រពាំងស្រង់ ឃុំស្កុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចុះបញ្ជីក្រោមលេខ ០០០២៣៥៦៤ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិឲ្យអ្នកកាន់អាជ្ញាបណ្ណគ្រប់គ្រងលើសេវាកម្មអគ្គិសនី និងដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់នៅក្នុងតំបន់អនុញ្ញាត ដែលកំណត់ក្នុងឧបសម្ព័ន្ធទី១ ។ | **Article 1**<br><br>To revise the license document No. 385 LD dated June 13, 2014, which was issued to **Mrs. Chan Kimeng**, for changing name of the licensee from **Mrs. Chan Kim Eng** to **Chan Kim Eng Electricity Co., Ltd.** (hereinafter referred to as "Licensee") located at Phum Trapeang Srang , Khum Skuh, Samrong Tong District, Kampong Speu Province in confirmity with the Commercial Registration in the Kingdom of Cambodia No. 00023564, dated February 16, 2017 pursuant under the regulations of commercial rules and register law, commercial enterprises law, civil code and penal code of the Kingdom of Cambodia for granting the right to the licensee to govern electric power service and to ensure electric power supply to consumers in authorized distribution area is determined in schedule 1. |
| **ប្រការ២**<br>បន្ថែមឧបសម្ព័ន្ធទី៤ " ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាបណ្ណ " លើឯកសារអាជ្ញាបណ្ណលេខ ៣៨៥ ឯអ ។ | **Article 2**<br>To add schedule 4 "Ownership of Licensee "on the license document No. 385 LD. |
| **ប្រការ៣**<br>ខ្លឹមសារ និងលក្ខខណ្ឌដទៃទៀតនៃឯកសារអាជ្ញាបណ្ណលេខ ៣៨៥ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 3**<br>The other contents and conditions of the license document No. 385 LD shall remain in force. |
| **ប្រការ៤**<br>សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាបណ្ណលេខ ៣៨៥ ឯអ ។ | **Article 4**<br>This decision shall be considered as a part of the license document No.385 LD. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ | **Article 5**<br>This decision shall come into force from the date of signing. |
| **ប្រការ៦**<br>អ្នកកាន់អាជ្ញាបណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាបណ្ណលេខ ៣៨៥ ឯអ បានតម្កល់ទុកពីមុនដើម្បីឲ្យឯកសារអាជ្ញាបណ្ណលេខ ៣៨៥ ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 385 LD has been deposited in order that the deposited license document No. 385 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៧

Phnom Penh, , 2017

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ឧបសម្ព័ន្ធទី ៤
# ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាបណ្ណ

## SCHEDULE 4

## OWNERSHIP OF LICENSEE

| | |
|---|---|
| ១- អ្នកកាន់អាជ្ញាបណ្ណមានម្ចាស់កម្មសិទ្ធិ ដែលបានចុះបញ្ជីក្នុងក្រុមហ៊ុន **ចាន់ គីមអេង អេឡិកទ្រីស៊ីធី** ឯ.ក គឺលោកស្រី **ចាន់ គីមអេង** ជាម្ចាស់ភាគហ៊ុនទាំងអស់ដែលមានចំនួន ១០០០ ភាគហ៊ុន។ | 1. Mrs. **Chan Kim Eng** is the single owner of **Chan Kim Eng Electricity Co., Ltd.** with 1000 shares. |
| ២- យោងតាមមាត្រា៤៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់កម្មសិទ្ធិដែលបានចុះបញ្ជីដូចខាងលើ ពុំអាចមានភាគហ៊ុន ឬមានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ជាមួយអ្នកកាន់អាជ្ញាបណ្ណផ្សេងទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ។ អាជ្ញាធរអគ្គិសនីកម្ពុជា អាចអនុញ្ញាតឲ្យបានក្នុងករណីពិសេស ដើម្បីជាផលប្រយោជន៍សាធារណៈ ។ | 2. Refer to Article 45 of the Electricity Law of the Kingdom of Cambodia, the above registered owners shall not own shares in or have any other direct financial interests in any other licensee without written permission from EAC. EAC may permit in special cases in public interest. |